Disability Rights California

*California's Protection & Advocacy System*

# របៀបទទួលបាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ក្រោមការចំណាយសាធារណៈ

*ខែមិថុនា ឆ្នាំ 2009, ឯកសារផ្សព្វផ្សាយ #5476.06-Cambodian*

**- តើលោកអ្នកមិនពេញចិត្ត នឹងការវាយតម្លៃ លើការអប់រំ ពិសេស របស់កូនលោកអ្នក នាពេលថ្មីៗ នេះ ឬ ?**

**- តើមណ្ឌលសាលា បដិសេធ សិទ្ធិទទួលបាន ការអប់រំ ពិសេស របស់កូនលោកអ្នក ឬ សេវាចាំបាច់ ឬ ការគាំទ្រ ដោយផ្អែកលើ អនុសាសន៍ ពីការវាយតម្លៃ ដែលធ្វើឡើង មិនបានល្អ ឬ ?**

**- តើលោកអ្នក បានស្នើសុំ ឱ្យមាន ការវាយតម្លៃ លក្ខណៈឯករាជ្យ លើកូនលោកអ្នក ហើយត្រូវបាន មណ្ឌលសាលា មិនអើពើ ឬ គ្រាន់តែប្រាប់មួយមាត់ថា "ទេ !" ឬ ?**

**ប្រសិនបើលោកអ្នកមានចម្លើយថា ពិតមែន ចំពោះសំណួរណាមួយ នៃសំណួរទាំងនេះ, នោះលោកអ្នក ចាំបាច់ត្រូវយល់ដឹង បន្ថែមទៀត អំពីសិទ្ធិ របស់លោកអ្នក ចំពោះការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ក្រោមចំណាយសាធារណៈ !!!**

## ច្បាប់

បទបញ្ញត្តិ ផ្នែកអប់រំ ពិសេស ចែងថា, ក្រោមលក្ខខណ្ឌ មួយចំនួន ៖

**"ឪពុក-ម្តាយ មានសិទ្ធិទទួលបាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ក្រោមចំណាយសាធារណៈ ប្រសិនបើឪពុក-ម្តាយនោះ មិនយល់ស្រប នឹងការវាយតម្លៃ ដែលទទួលបាន ដោយទីភ្នាក់ងារ  សាធារណៈ"[1]**

បទបញ្ញត្តិ ផ្នែកអប់រំ ពិសេស សហព័ន្ធ ក៏ចែងថា ប្រសិនបើឪពុក-ម្តាយស្នើសុំ ឱ្យមាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ (IEE) ក្រោមចំណាយសាធារណៈ, នោះ ដោយមិនត្រូវមានការពន្យារពេល មិនចាំបាច់ណាមួយ, មណ្ឌលសាលា ត្រូវ ៖

- *ដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ក្នុងការបើកសវនការ ដើម្បីបង្ហាញថា ការវាយតម្លៃរបស់ខ្លួន មានលក្ខណៈសមស្រប ។*[2]

ឬ

- *ធានាថា ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ត្រូវបានផ្តល់ជូន ក្រោមចំណាយសាធារណៈ, លើកលែងតែ ទីភ្នាក់ងារនោះ បង្ហាញនៅក្នុងសវនការ អនុលោមតាម §§ 300.507 រហូតដល់ 300.513 ថា ការវាយតម្លៃ ដែលឪពុក-ម្តាយ ទទួលបាននោះ មិនបំពេញបាន តាមលក្ខណៈវិនិច្ឆ័យ របស់ទីភ្នាក់ងារ ឡើយ ។*

នេះ មានន័យថា ប្រសិនបើលោកអ្នក ស្នើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ, នោះមណ្ឌលសាលា មានជម្រើស តែពីរ ប៉ុណ្ណោះ ៖ 1) ចាត់ វិធានការចាំបាច់នានា ដើម្បីធានាថា លោកអ្នកទទួលបាន IEE ដោយគ្មានបន្ទុកចំណាយសម្រាប់លោកអ្នក, ឬ 2) ដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច និង ព្យាយាមបង្ហាញភស្តុតាង ជូន ចៅក្រមច្បាប់រដ្ឋបាល ថា ការវាយតម្លៃរបស់ខ្លួន មានលក្ខណៈសមស្រប ។ នេះ គឺជា បញ្ញត្តិមួយ នៃបញ្ញត្តិគួរជាទីពេញចិត្តបំផុត សម្រាប់ឪពុកម្តាយ នៅក្នុង ច្បាប់អប់រំពិសេស ទាំងអស់

---

[1] 34 C.F.R. § 300.502 (b) (1) ។ "ត្រឡប់ទៅឯកសារមេ"

[2] លេខសម្គាល់។ នៅ (b) (2) ។ "ត្រឡប់ទៅឯកសារមេ"

ដោយសារ ការចូលរួមសវនការ អាចមាន ឬ មាន បន្ទុកចំណាយខ្ពស់ សម្រាប់មណ្ឌលសាលា ជាជាង ការយល់ព្រម ទូទាត់ថ្លៃចំណាយ លើ IEE ។ **ក្នុងផ្លូវច្បាប់ មណ្ឌលសាលា មិនអាច មិនអើពើ នឹងលោកអ្នក ឬ គ្រាន់តែប្រាប់លោកអ្នកថា “ទេ” នោះទេ ។**

## របៀបអនុវត្តន៍

ទាំងនេះ គឺជា ជំហ៊ាននានា ដែលលោកអ្នកត្រូវការ ដើម្បីទទួលបាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ (IEE) ក្រោមចំណាយសាធារណៈ ៖

1. **ដាក់សំណើ ជាលាយល័ក្ខណ៍អក្សរ ស្នើសុំឱ្យមាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ក្រោមចំណាយសាធារណៈ**

ចំណុចទីមួយ ដែលលោកអ្នកត្រូវធ្វើ គឺត្រូវសរសេរលិខិត ទៅជនបង្គោល របស់ក្រុមការងារ IEP ឬ អ្នកគ្រប់គ្រងសាលា ដោយបញ្ជាក់ថា លោកអ្នកមិនយល់ស្រមនឹង ការវាយតម្លៃ របស់មណ្ឌលសាលា និងស្នើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ ។ ទោះបិជាមណ្ឌលសាលា អាចស្នើឱ្យលោកអ្នក ធ្វើការពន្យល់ ពីមូលហេតុ ដែលលោកអ្នកគិតថា ការវាយតម្លៃនោះ មានលក្ខណៈមិនសមស្រប ក្តី, ក៏លោកអ្នកត្រូវតែផ្តល់ មូលហេតុណាមួយ ដែលលោកអ្នក មិនយល់ស្រប ជាមួយមណ្ឌលសាលា ដែរ ។ ជាមួយនេះផងដែរ, មណ្ឌលសាលា អាចមិនប្រើប្រាស់ ការបដិសេធ មិនព្រមពន្យល់ ពីការមិនយល់ស្រប របស់លោកអ្នក ជាលេស ដើម្បីពន្យារពេល មិនឆ្លើយតបនឹង សំណើ របស់លោកអ្នក  ដែរ ។[3]

នៅគ្រប់សំណើ ដែលលោកអ្នកដាក់ ចំពោះមណ្ឌលសាលា, វាគួរធ្វើឡើង ជាលាយល័ក្ខណ៍អក្សរ ហើយលោកអ្នកគួររក្សាទុក ឯកសារសំណើ មួយច្បាប់ សម្រាប់ខ្លួនឯង ។ គំនិតល្អ មួយទៀត គឺត្រូវផ្ញើរ ច្បាប់ចម្លងសំណើ ទៅការិយាល័យអប់រំពិសេស ប្រចាំមណ្ឌល ជាបន្ថែមលើ មន្ត្រីក្នុងសាលា ដែលមានបញ្ជាក់ឈ្មោះ ជាអ្នកទទួល នៅក្នុងសំណើនោះ ។ ទោះបីជា ច្បាប់ មិនបានចែងថា សំណើ សុំឱ្យមាន IEE ត្រូវធ្វើ ជាលាយល័ក្ខណ៍អក្សរក្តី, ក៏ការមាន ភស្តុតាង ដែលបញ្ជាក់ថា សំណើ ត្រូវបានធ្វើ ជាលាយល័ក្ខណ៍អក្សរនោះ គឺមានសារៈសំខាន់ ដោយសារមណ្ឌលសាលា មិនត្រូវបាន តម្រូវឱ្យ

---

[3] លេខសម្គាល់។ នៅ (b) (4) ។ "ត្រឡប់ទៅឯកសារមេ"

សងប្រាក់ត្រឡប់វិញ ជូនលោកអ្នក សម្រាប់ IEE នោះទេ ប្រសិនបើលោកអ្នក មិនបានផ្តល់ សេចក្តីជូនដំណឹង ជាមុន ដល់មណ្ឌល ដើម្បីបញ្ជាក់ថា លោកអ្នកមិនយល់ស្រប នឹងការវាយតម្លៃ និងសំណើ សុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ នោះ ។ ការមានសំណៅឯកសារលិខិតស្នើសុំ មួយច្បាប់ទុក គឺជា មធ្យោបាយល្អបំផុត ដើម្បីបញ្ជាក់ថា លោកអ្នកគោរពតាម នីតិវិធីទាំងនេះ ប្រសិនបើមានវិវាទ នាពេលក្រោយទៀត ។

## 2. រង់ចាំការឆ្លើយតប

មុនពេលធ្វើអ្វីមួយ, លោកអ្នកគួររង់ចាំ ក្នុងកំឡុងពេលសមស្របមួយ ក្រោយពេលដាក់ សំណើរបស់លោកអ្នក រួច ដើម្បីផ្តល់ឱកាសដល់ មណ្ឌលសាលា ក្នុងការឆ្លើយតប ។ ទាំង ច្បាប់អប់រំពិសេស នៅកាលីហ្វ័រញ៉ា និងនៅកម្រិតសហព័ន្ធ មិនបានកំណត់ ពី ថេរវេលា ឬ ចំនួនថ្ងៃ សម្រាប់ឱ្យ មណ្ឌលសាលា ត្រូវការផ្តល់ IEE ក្រោមចំណាយសាធារណៈ ឬ ដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ក្រោយពេលមានសំណើ នោះទេ ។ ច្បាប់អប់រំពិសេស នៅកាលីហ្វ័រញ៉ា និងនៅកម្រិតសហព័ន្ធ គ្រាន់តែចែងថា មណ្ឌលសាលា ត្រូវដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ឬធានាថា IEE ត្រូវបានផ្តល់ជូន ដោយគ្មាន ការពន្យារពេល ដែលពុំចាំបាច់ នោះឡើយ ។ រដ្ឋផ្សេងៗ ទៀត ដែលបានអនុវត្ត ថេរវេលា ជាក់លាក់ ធ្វើការតម្រូវឱ្យ រដ្ឋផ្តល់ការឯកភាព លើ IEE ឬ ដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ក្នុងថេរវេលា ណាមួយ នៅចន្លោះ ពី 5 ទៅ 30 ថ្ងៃ ក្រោយទទួលបានសំណើ ពីឪពុក-ម្តាយ ដែរ ។[4] នៅកាលីហ្វ័រញ៉ា, តុលាការមួយ បានរកឃើញថា មានការពន្យារពេល មិនចាំបាច់ នៅពេលមណ្ឌលសាលា បានរង់ចាំ អស់រយៈពេល 3 ខែ ក្រោយមានសំណើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ[5] មុនពេលធ្វើការដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ដំណើរការ ។ តុលាការ ក្នុងករណីនេះ

---

[4] ឧទាហរណ៍ Maine អនុញ្ញាតឱ្យសាលារៀនស្រុក 30 ថ្ងៃប្រតិទិនយល់ព្រមដើម្បីផ្តល់ IEE ឬឯកសារសម្រាប់ដំណើរការត្រឹមត្រូវ។ រដ្ឋ Louisiana អនុញ្ញាតឱ្យមានថ្ងៃសិក្សា 10 ថ្ងៃ។ រដ្ឋ Michigan អនុញ្ញាតឱ្យ 7 ថ្ងៃប្រតិទិន; និងម៉ាសាជូសេតអនុញ្ញាតឱ្យមានសាលារៀនចំនួន 5 ថ្ងៃ។ "ត្រឡប់ទៅឯកសារមេ"

[5] Pajaro ជ្រលងបង្រួបបង្រួម Sch ។ ខណ្ឌ។ v ។ J.S. , 47 IDELR 12, 50 (N.D. Cal ។ , 2006) ។ "ត្រឡប់ទៅឯកសារមេ"

មិនបានបដិសេធចោល ការរកឃើញថា ថេរវេលា ខ្លីជាងនេះទៀត ក៏អាចធ្វើឱ្យមាន ការពន្យារពេល ដែលពុំចាំបាច់ ដែរ, ប៉ុន្តែ ក៏មិនបាន ផ្តល់គម្រុយណាមួយ បញ្ជាក់ថា គួរប្រើ កត្តាណា ដើម្បីធ្វើការកំណត់ពី ការពន្យារពេល ដែលពុំចាំបាច់ នោះឡើយ ។ ទោះជាយ៉ាងនេះក្តី, មានភាពច្បាស់លាស់ ពីពាក្យសំដី របស់ករណីថា នៅពេលមាន ការពន្យារពេល ដែលពុំចាំបាច់, មណ្ឌលធ្វើការលះបង់សិទ្ធិ ក្នុងការតតាំង នឹងសំណើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ[6] ដោយមិនគិតពីសុពលភាព នៃការវាយតម្លៃ របស់ខ្លួន យើងខ្ញុំណែនាំ ឱ្យរង់ចាំ ក្នុងថេរវេលា សមហេតុផលមួយ ក្រោយពេលដាក់ សំណើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ មុនពេលដាក់ ពាក្យបណ្តឹងណាមួយនោះ ។ ពេលវេលា សមហេតុផល ត្រូវរង់ចាំ អាចមាន រយៈពេល 15 ថ្ងៃសិក្សា ដោយសារវាជា ថេរវេលា ដែលមណ្ឌលសាលាមាន ចាប់ពីពេលទទួលបាន សំណើពីឪពុកម្តាយ ដើម្បីបង្ហាញពី ផែនការវាយតម្លៃ នៅពេលមណ្ឌល ធ្វើការវាយតម្លៃ ដោយខ្លួនឯងផ្ទាល់ ។

### 3. សូមកុំទទួលចម្លើយ ទេ ឱ្យសោះ

ប្រសិនបើមណ្ឌលផ្តល់ការឯកភាព លើ IEE, នោះបន្ទាប់មក ត្រូវធ្វើការ ជាមួយមណ្ឌល ដើម្បីកំណត់រក កត្តាភស្តុភារនានា សម្រាប់ទទួលបាន ការវាយតម្លៃ លក្ខណៈឯករាជ្យ ។ ប្រសិនបើ មណ្ឌលដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច, ត្រូវត្រៀមលក្ខណៈ ចូលរួមសវនការ ដើម្បីផ្តល់ ការពន្យល់ ជូន ចៅក្រមច្បាប់រដ្ឋបាល ពីមូលហេតុ ដែលលោកអ្នកគិតថា ការវាយតម្លៃ របស់មណ្ឌលសាលា មានលក្ខណៈមិនសមស្រប និងពីមូលហេតុ ដែលលោកអ្នក ត្រូវការ IEE ។ លោកអ្នកក៏គួរ ទូរសព្ទទៅ ផ្នែកសិទ្ធិជនពិការ កាលីហ្វ័រញ៉ា ហើយរកឱ្យបាន ឯកសារ អំពីជំពូក នៃសៀវភៅណែនាំ ស្តីពីសិទ្ធិទទួលបានការអប់រំពិសេស និងការទទួលខុសត្រូវ មួយច្បាប់ ដែលពន្យល់ពី ដំណើការ ជាកាតព្វកិច្ច ។

---

[6]លេខសម្គាល់។("ការពន្យាពេលមិនច្បាស់លាស់និងមិនចាំបាច់ក្នុងការដាក់ពាក្យសម្រាប់សវនាការនីតិវិធីត្រឹមត្រូវរបស់សាលាក្តីនេះបានលើកលែងពីសិទ្ធិរបស់ខ្លួនដើម្បីធ្វើការតវ៉ាចំពោះការស្នើសុំរបស់សិស្សចំពោះការវាយតម្លៃអប់រំឯករាជ្យនៅឯការចំណាយសាធារណៈនិងដោយខ្លួនវាផ្ទាល់ដែលតម្រូវឱ្យចូលសាលក្រមដើម្បីគាំទ្រដល់សិស្ស" ។ ទៅឯកសារសំខាន់ "

ប្រសិនបើក្រោយពេលរង់ចាំ ក្នុងរយៈពេល សមស្របមួយ រួច, សាលាមិនបានឆ្លើយតប ទៅនឹងសំណើលោកអ្នក ឬបានបដិសេធ សំណើលោកអ្នក ដោយគ្មានដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ដាកាតព្វកិច្ចនោះ, លោកអ្នកអាចសម្រេច សរសេរលិខិតមួយទៀត ជូនដំណឹងទៅ មណ្ឌលសាលាថា ពួកគេបានរំលោភបំពាន លើសិទ្ធិលោកអ្នក ក្រោម ផ្នែក 300.502(b) នៃ ចំណងជើង 34 នៃ ក្រោមបទបញ្ញត្តិសហព័ន្ធ ។ នៅក្នុងលិខិតនេះ លោកអ្នកក៏អាចរំឭកប្រាប់ មណ្ឌលសាលាថា លោកអ្នកចាត់ទុក ការមិនចាត់វិធានការ របស់ពួកគេ ជា ចម្លើយបញ្ជាក់ ចំពោះសំណើលោកអ្នក ហើយ អាច ៖ 1) ជូនដំណឹង ដល់មណ្ឌលថា លោកអ្នក នឹងទូទាត់ចំណាយ លើ IEE ដោយខ្លួនឯង និងបង្ហាញ វិក្កយបត្រ ជូនទៅ មណ្ឌលសាលា ដើម្បីទទួលបាន ប្រាក់សងត្រឡប់វិញ, ឬ 2) ស្នើសុំឱ្យ មណ្ឌលសាលា រៀបចំណាត់ការធ្វើការទូទាត់ ជាមួយ អ្នកផ្តល់សេវា ដែលលោកអ្នកបាន ជ្រើសរើស ដើម្បីធ្វើ IEE របស់លោកអ្នក ។ លោកអ្នកក៏អាចសម្រេច មិននិយាយអ្វីទាំងអស់ ជាមួយ មណ្ឌលសាលា ហើយបន្តទៅ ជំហ៊ាន ទី 4 ។

## 4. ប្រសិនបើនៅតែបរាជ័យទាំងអស់, សូមដាក់ ពាក្យបណ្តឹង ករណីអនុលោមភាព ។

ប្រសិនបើមណ្ឌលសាលា នៅតែមិនផ្តល់ ការឯកភាព លើ IEE ឬដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ដាកាតព្វកិច្ច, នោះលោកអ្នកគួរតែ ដាក់ពាក្យបណ្តឹង ករណីអនុលោមភាព ទៅក្រសួងអប់រំកាលីហ្វ័រញ៉ា (CDE) ។ នៅក្នុងពាក្យបណ្តឹងនេះ លោកអ្នកគួរធ្វើការចោទប្រកាន់ថា មណ្ឌលសិក្សា បានរំលោភបំពាន លើសិទ្ធិ ផ្នែកនីតិវិធី របស់លោកអ្នក ក្រោម 34 C.F.R. §300.502(b) ហើយស្នើសុំឱ្យមាន ការប៉ះប៉ូវ ដែល CDE បញ្ជាទៅ មណ្ឌលសាលា ឱ្យផ្តល់ IEE ដល់លោកអ្នក ភ្លាមៗ ។ លោកអ្នកគួរភ្ជាប់ជាមួយ ពាក្យបណ្តឹង នូវ ច្បាប់ចម្លង នៃសំណើសុំ IEE របស់លោកអ្នក និងឯកសារផ្សេងៗ ទៀត ផ្ញើចេញពីលោកអ្នក ឬ មណ្ឌលសាលា ដែលអាចជួយ CDE ឱ្យអាចធ្វើការសម្រេច បម្រើឱ្យផលប្រយោជន៍លោកអ្នកបាន ។ ជាទូទៅ CDE មានរយៈពេល 60 ថ្ងៃ ដើម្បីចេញ សេចក្តីសម្រេច ចាប់ពីពេលដាក់ពាក្យបណ្តឹង ។ ពាក្យបណ្តឹង ករណីអនុលោមភាព អាចដាក់បាន ជាលាយល័ក្ខណ៍អក្សរ ទៅ ៖

California Department of Education
1430 “N” Street, Suite 2401
Sacramento, CA 95814-5901

សម្រាប់ការពិនិត្យ លក្ខណៈស៊ីជម្រៅ លើពាក្យបណ្តឹង ករណីអនុលោមភាព, លោកអ្នកគួរអាន ជំពូក ទី 6 នៃសៀវភៅ ស្តីពីសិទ្ធិទទួលបានការអប់រំពិសេស និងការទទួលខុសត្រូវ របស់ DRC ។

## សំណួរឧស្សាហ៍ចោទឡើង

### តើខ្ញុំអាចជ្រើសរើសនរណាបាន ដើម្បីឱ្យធ្វើ IEE របស់កូនខ្ញុំ ?

ដោយមិនគិតថាតើ មណ្ឌលយល់ស្រប ក្នុងការផ្តល់ IEE ជូនលោកអ្នក ឬ សម្រេចដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ឬអត់នោះ, មណ្ឌលសាលា ត្រូវផ្តល់ជូនលោកអ្នក នូវ "ព័ត៌មាន អំពីទីកន្លែង ដែលអាចទទួលបាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ, និងលក្ខណវិនិច្ឆ័យទីភ្នាក់ងារ ដែលពាក់ព័ន្ធ សម្រាប់ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យការវាយតម្លៃ ។"[7] ព័ត៌មាននេះ គួររួមមាន បញ្ជីអ្នកវាយតម្លៃ មានគុណវុឌ្ឍន៍ នៅក្នុងតំបន់លោកអ្នក, ព្រមទាំង គោលការណ៍ណែនាំ ស្តីពីថ្លៃ និងបទដ្ឋានផ្សេងៗ ទៀត ដែលមណ្ឌលបានអនុម័តរួច ។ ខណៈដែលលោកអ្នក មិនជាប់កាតព្វកិច្ច ក្នុងការប្រើ អ្នកវាយតម្លៃ ដូចមានរាយក្នុងបញ្ជី ដោយមណ្ឌលសាលាក្តី, ការទៅរក អ្នកក្រៅ ខុសពីការឱ្យយោបល់ ឬគោលការណ៍ណែនាំ របស់ពួកគេ អាចនាំឱ្យមាន វិវាទ លើការទូទាត់ហួស ប្រាក់កម្រិត ឬលើការសងប្រាក់ត្រឡប់វិញ ។ ដើម្បីជៀសវាងវិវាទបែបនេះ ត្រូវប្រាកដថា អ្នកវាយតម្លៃ ដែលលោកអ្នកជ្រើសរើស បំពេញបានតាម កម្រិតគុណវុឌ្ឍន៍ទាំងអស់ ដែលមានក្នុង លក្ខណវិនិច្ឆ័យទីភ្នាក់ងារ ។ ប្រសិនបើមណ្ឌលមានលក្ខណៈ មិនសមហេតុផល ដោយដាក់កម្រិត ចំពោះលោកអ្នក ក្នុងវិសាលភាព ដែលធ្វើឱ្យការវាយតម្លៃ មិនមានលក្ខណៈឯករាជ្យ ពិតប្រាកដ, នោះលោកអ្នកគួរដាក់ ពាក្យបណ្តឹង ករណីអនុលោមភាព ដោយផ្អែកលើ ការខកខាន របស់មណ្ឌល ក្នុងការធានា ឱ្យមានការផ្តល់នូវ IEE ក្រោមចំណាយសាធារណៈ ដោយគ្មានការពន្យារពេល ដែលពុំចាំបាច់នោះ ។

[7] 34 C.F.R. § 300.502 (a) (2) ។ "ត្រឡប់ទៅឯកសារមេ"

**ចុះប្រសិនបើខ្ញុំគ្មានប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់លើ IEE បានភ្លាមៗ ហើយមណ្ឌលបញ្ជាក់ថា ការសងប្រាក់ត្រឡប់វិញ នាពេលក្រោយ គឺជា ជម្រើសតែមួយគត់ ដែលមាននោះ ?**

ច្បាប់ និងបទបញ្ញត្តិ សម្រាប់ការអប់រំពិសេស មិនមានកំណត់ លក្ខណៈដែលមណ្ឌលត្រូវកំណត់រក ភស្តុភារទ្រទ្រង់ ការផ្តល់ IEE ក្រោមចំណាយសាធារណៈនោះទេ ។ ទោះជាយ៉ាងនេះក្តី, ប្រសិនបើលោកអ្នកគ្មានលទ្ធភាពទូទាត់ លើ IEE បានភ្លាមៗ ហើយមកទទួលប្រាក់សងត្រឡប់វិញទេនោះ, មណ្ឌលគួររៀបចំ ចំណាត់ការផ្សេងទៀត ដូចជាការទូទាត់ ជូនអ្នកវាយតម្លៃ ឯកជន ដោយផ្ទាល់, ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងការធានាថា IEE ត្រូវបានផ្តល់ជូន ដោយគ្មានការពន្យារពេលដែលពុំចាំបាច់នោះ ។ ប្រសិនបើមណ្ឌលបដិសេធ មិនធ្វើការកំណត់រក ចំណាត់ការសមហេតុផលទេ, នោះលោកអ្នកគួរ ដាក់ ពាក្យបណ្តឹង ករណីអនុលោមភាព ។

**ប្រសិនបើខ្ញុំមានប្រាក់, តើខ្ញុំគួរទូទាត់លើ ការវាយតម្លៃ ដោយខ្លួនឯង ហើយមកយក ប្រាក់សងត្រឡប់វិញ ពីមណ្ឌលសាលា បានដែរឬទេ ?**

ក្នុងនាមជា ឪពុក-ម្តាយ, លោកអ្នកតែងតែ មានសិទ្ធិទទួលបាន IEE ក្រោមបន្ទុកចំណាយ របស់លោកអ្នកផ្ទាល់ ហើយដាក់ឱ្យ មណ្ឌលធ្វើការពិចារណាលើការវាយតម្លៃនោះ ដើម្បីកសាង កម្មវិធីអប់រំ សម្រាប់កូនលោកអ្នកក IEP[8]. ប៉ុន្តែ លោកអ្នក មិនគួរធ្វើការទូទាត់ លើការវាយតម្លៃ លក្ខណៈឯករាជ្យ ដោយប្រាក់ពីហោប៉ៅលោកអ្នក ដោយមិនបានស្នើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ ពីមណ្ឌល ហើយទុកពេល ឱ្យមណ្ឌលឆ្លើយតប ជាមុនសិន នោះទេ ។ ប្រសិនបើលោកអ្នកទទួលបាន ការវាយតម្លៃ លក្ខណៈឯករាជ្យ ក្រោមបន្ទុកចំណាយ របស់លោកអ្នកផ្ទាល់ រួចហើយ, មណ្ឌលសាលា មិនជាប់កាតព្វកិច្ច ត្រូវផ្តល់ជូន ប្រាក់សងត្រឡប់វិញ នោះទេ លើកលែងតែលោកអ្នកអាច បញ្ជាក់បានថា លោកអ្នកបានជូនដំណឹង ដល់មណ្ឌលសាលាថា លោកអ្នកមាន ការមិនយល់ស្រប នឹងការវាយតម្លៃ របស់ពួកគេ ហើយបានស្នើសុំឱ្យមាន IEE ។

---

[8] លេខសម្គាល់។ នៅ (ក), (គ) (1) ។ "ត្រឡប់ទៅឯកសារមេ"

## តើការវាយតម្លៃ ប្រភេទអ្វី ដែលខ្ញុំអាច ស្នើសុំ ជា IEE ក្រោមចំណាយសាធារណៈបាននោះ ?

ដោយសារគ្មានការកំណត់ ក្នុងច្បាប់, ទើបលោកអ្នកអាចស្នើសុំឱ្យមាន ការវាយតម្លៃ ប្រភេទណាក៏បាន ដែលមណ្ឌលសាលា អាចនឹងធ្វើ ដើម្បីវាយតម្លៃ លើសិទ្ធិអាចទទួលបាន ការអប់រំពិសេស ឬលើសេចក្តីត្រូវការ លើការអប់រំ របស់កូនលោកអ្នក ចំពោះផ្នែកពិការភាព ដែលមានការសង្ស័យ ។ នេះរួមមាន មិនត្រឹមតែ ការវាយតម្លៃ លើផ្នែកចិត្តសាស្ត្រអប់រំ នោះទេ ថែមទាំង ការវាយតម្លៃ កាន់តែមាន លក្ខណៈឯកទេស ថែមទៀត ដូចជា ការវាយតម្លៃ លើបច្ចេកវិទ្យាជំនួយ, ការវាយតម្លៃ លើការនិយាយស្តី, ការវាយតម្លៃ លើការព្យាបាល ផ្នែកការងារ និង ការវាយតម្លៃ លើការវិភាគ ផ្នែកមុខងារ ។ ទោះជាយ៉ាងនេះក្តី, ត្រូវប្រាកដថា មណ្ឌលសាលា បានធ្វើការវាយតម្លៃ ទៅតាមប្រភេទ ដែលលោកអ្នកចង់បាន ដោយសារសំណើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ ត្រូវផ្អែកលើ ការមិនយល់ស្រប របស់ឪពុក-ម្តាយ ចំពោះការវាយតម្លៃ ដែលមានស្រាប់ នាពេលបច្ចុប្បន្ន ដែលទទួលបានពី មណ្ឌលសាលា ។ ទាំងច្បាប់ និងបទបញ្ញត្តិ សុទ្ធតែគ្មាន ការដាក់កម្រិតណាមួយ លើអាយុកាល របស់ការវាយតម្លៃ ដែលត្រូវមាននោះទេ, ហេតុនេះ ជាទូទៅ លោកអ្នកអាចស្នើសុំ ឱ្យមាន IEE ក្រោមចំណាយសាធារណៈ ដោយផ្អែកលើការមិនយល់ស្រប របស់លោកអ្នក ចំពោះការវាយតម្លៃ ដែលមានអាយុកាល បីបួនឆ្នាំ បាន ឱ្យតែវាជាលើកទីមួយ ដែលលោកអ្នកស្នើសុំឱ្យមាន ការវាយតម្លៃ ហើយវាជា ការវាយតម្លៃថ្មី ចុងក្រោយបំផុតនោះ ។

## តើមណ្ឌលសាលា អាចដាក់កម្រិត លើអ្នកវាយតម្លៃ លក្ខណៈឯករាជ្យ មិនឱ្យធ្វើការវាយតម្លៃកូនខ្ញុំ នៅទីធ្លាសាលា រួមទាំង បរិស្ថានថ្នាក់រៀន ដែរឬទេ ?

ទេ ។ ប្រសិនបើមណ្ឌលសាលា ធ្វើការវាយតម្លៃ ដែលមានការតវ៉ា ដោយប្រើការសង្កេត នៅក្នុងថ្នាក់នោះ, ឬ ប្រសិនបើការសង្កេត នៅក្នុងថ្នាក់ អាចជា វិធីដែលមានការអនុញ្ញាត សម្រាប់ឱ្យអ្នកវាយតម្លៃ របស់មណ្ឌលសាលាប្រើនោះ, ឱកាសដូចគ្នា គួរត្រូវផ្តល់ជូនទៅ អ្នកវាយតម្លៃឯករាជ្យ ដែរ ។ នេះរួមមាន ការសង្កេត លើស្ថានភាព និងបរិបទអប់រំបច្ចុប្បន្ន និងលើស្ថានភាព និងបរិបទអប់រំថ្មី ដែលបានស្នើឡើង ដោយមណ្ឌលសាលា, ដោយមិនគិតថាតើ លោកអ្នកបានស្នើសុំឱ្យមាន IEE

នៅមុនពេល ឬនៅក្រោយពេល ដាក់ ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច ដើម្បីបើកសវនការ នោះឡើយ ។[9]

**តើខ្ញុំអាចស្នើសុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ បានប៉ុន្មានដង ?**

បទបញ្ញត្តិសហព័ន្ធ ចែងថា ឪពុកម្តាយ “មានសិទ្ធិទទួលបាន ការវាយតម្លៃ លើការអប់រំ លក្ខណៈឯករាជ្យ ក្រោមចំណាយសាធារណៈ តែម្តងគត់ នៅរាល់ពេល ដែលទីភ្នាក់ងារ សាធារណៈធ្វើការវាយតម្លៃ ដែលឪពុកម្តាយមិនយល់ស្របនោះ មិនយល់ស្រប ។”[10] ប្រសិនបើលោកអ្នក មិនសប្បាយចិត្ត ជាមួយ IEE ដែលទទួលបាន ក្រោមចំណាយសាធារណៈ, នោះលោកអ្នកនឹងត្រូវរង់ចាំឱ្យ មណ្ឌលសាលាធ្វើការវាយតម្លៃឡើងវិញ លើកូនលោកអ្នក មុនពេលលោកអ្នក អាចស្នើសុំឱ្យមាន IEE មួយទៀត ក្រោមចំណាយសាធារណៈ ។

**ហេតុអ្វីខ្ញុំគួរដាក់ ពាក្យបណ្តឹង ករណីអនុលោមភាព ជាជាង ពាក្យបណ្តឹងស្នើសុំ ឱ្យមានដំណើរការ ជាកាតព្វកិច្ច នោះ ?**

ដំណើរការពាក្យបណ្តឹង ករណីអនុលោមភាព គឺជា ផ្នែកដ៏ធំ ដែលកំណត់ឡើង ដើម្បីធានាថា មណ្ឌលសាលា អនុត្តតាម លក្ខខណ្ឌតម្រូវ ផ្នែកនីតិវិធី របស់ច្បាប់អប់រំពិសេស ។ ក្នុងពាក្យបណ្តឹង ករណីអនុលោមភាព, CDE ធ្វើការស៊ើបអង្កេតលើ ការរំលោភបំពាន ផ្នែកនីតិវិធី ហើយបញ្ជាឱ្យ មណ្ឌល ចាត់វិធានការ កែតម្រូវ ប្រសិនបើមានរកឃើញមែន ។ ជាទូទៅ ដំណើរការនេះ តម្រូវឱ្យមាន សកម្មភាពតិចតួច ពីឪពុក-ម្តាយ នៅពេលបានដាក់ ពាក្យបណ្តឹង រួច ។ ទន្ទឹមនឹងនោះ, បញ្ហា នឹងមិនស្ថិតនៅត្រង់ថាតើ ការវាយតម្លៃ របស់មណ្ឌល មានលក្ខណៈសមស្រប ឬអត់នោះទេ, ប៉ុន្តែស្ថិតនៅត្រង់ថាតើ ពួកគេមានពាក់ព័ន្ធនឹង ការពន្យារពេល ដែលពុំចាំបាច់ ក្នុងការឆ្លើយតប ឱ្យបានសមស្រប ទៅនឹងសំណើ របស់លោកអ្នក សុំឱ្យមាន IEE ក្រោមចំណាយសាធារណៈ ឯណោះទេ ។

ផ្ទុយទៅវិញ ដំណើរការ ជាកាតព្វកិច្ច គឺជា សវនការ បែបរដ្ឋបាល នៅចំពោះមុខ ចៅក្រមច្បាប់រដ្ឋបាល នោះទេ ។ ទោះបីជា រយៈពេល មានខ្លីជាងបន្តិច បណ្តឹង

---

[9] Cal ។ Ed ។ ក្រម§ 56329 (b) ។ "ត្រឡប់ទៅឯកសារមេ"

[10] 34 C.F.R. § 300.502 (b) (5) ។ "ត្រឡប់ទៅឯកសារមេ"

ករណីអនុលោមភាពក្តី, ក៏ សវនការ នៃដំណើរការ ជាកាតព្វកិច្ច អាចមានលក្ខណ:បំភិតបំភ័យ ដល់ឪពុកម្តាយ ដោយសារវាមាន លក្ខណ:ដូចអង្គជំនុំជម្រះ ហើយមណ្ឌលសាលា ស្ទើរតែជានិច្ចជាកាល ត្រូវបានតំណាងឱ្យ ដោយមេធាវី ម្នាក់ ។ លើសពីនេះទៅទៀត, សេចក្តីសម្រេច របស់តុលាការកំពូល ធ្វើឱ្យវា កាន់តែមានលក្ខណ:ពិបាកឡើង សម្រាប់ឪពុកម្តាយ ដែលដាក់ ពាក្យបណ្តឹង ស្នើសុំឱ្យមាន ដំណើរការ ជាកាតព្វកិច្ច ដើម្បីតវ៉ា ដោយវាបានដាក់ បន្ទុកផ្តល់ភស្តុតាង លើភាគីដាក់ពាក្យបណ្តឹង ស្នើសុំឱ្យមាន ដំណើរការ ជាកាតព្វកិច្ច ដំណើរការ ។ ហេតុនេះ[11], ជាធម្មតា ការដាក់ពាក្យបណ្តឹង ករណីអនុលោមភាព គឺជា យុទ្ធសាស្ត្រ ប្រសើរជាង ។ ទោះជាយ៉ាងនេះក្តី, ប្រសិនបើលោកអ្នក មានផែនការដាក់ ពាក្យបណ្តឹង ដំណើរការ ជាកាតព្វកិច្ច លើបញ្ហាផ្សេងទៀតផងដែរ, សូមណែនាំលោកអ្នក ឱ្យរួមបញ្ចូល ការរំលោភបំពាន ដែលពាក់ព័ន្ធនឹង ការផ្តល់ IEE ក្រោមចំណាយសាធារណ: ជាផ្នែក នៃសំណើរសុំឱ្យមាន ដំណើរការ ជាកាតព្វកិច្ច ចំពោះករណីបញ្ហាច្រើន ។

---

យើងខ្ញុំចង់ដឹង ពីយោបល់លោកអ្នក ! សូមបំពេញ កម្រងសំណួរអង្កេត អំពីការផ្សព្វផ្សាយ របស់យើងខ្ញុំ ហើយប្រាប់យើងខ្ញុំ ពីយោបល់លោកអ្នកផង ! [សូមបំពេញ កម្រងសំណួរអង្កេត]

សម្រាប់ជំនួយផ្នែកច្បាប់ សូមហៅទូរសព្ទ ទៅលេខ 800-776-5746 ឬ បំពេញ ទម្រង់បែបបទសំណើ សុំជំនួយ។ សម្រាប់គោលបំណងផ្សេងៗ ទៀត សូមទៅទូរសព្ទ ទៅលេខ 916-504-5800 (កាលីហ្វ័រញ៉ាខាងជើង); 213-213-8000 (កាលីហ្វ័រញ៉ាខាងត្បូង) ។

*ផ្នែកសិទ្ធិជនពិការ កាលីហ្វ័រញ៉ា ទទួលបានមូលនិធិ ពីប្រភព យ៉ាងច្រើន, សម្រាប់បញ្ជីអ្នកផ្តល់មូលនិធិ ពេញលេញ, សូមចូលទៅ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។

---

[11] Schaffer v ។ Weast, 546 សហរដ្ឋអាមេរិក 49 (2005) ។
"ត្រឡប់ទៅឯកសារមេ"